# អបអរសាទរ ទិវាជាតិសុខភាពមាតា ទារក និងកុមារឆ្នាំ២០១៥

## របាយការណ៍សមិទ្ធិផលសុខាភិបាលលើផ្នែកសុខភាពមាតា ទារកនិងកុមារ ពីឆ្នាំ២០០០ដល់ឆ្នាំ២០១៤

១.អត្រាមរណភាពមាតា (Maternal Mortality Ratio) នៅកម្ពុជាបានថយចុះ គួរឲ្យកត់សំគាល់ ពី៤៣៧ក្នុងមួយសែនកំណើតរស់នៅឆ្នាំ២០០០ មកដល់២០៦ នៅឆ្នាំ២០១០ និងនៅឆ្នាំ២០១៤អត្រានេះបានធ្លាក់ចុះមកនៅត្រឹម១៧០ ក្នុងមួយសែនកំណើតរស់។




២.អត្រាមរណភាពទារកទើបនឹងកើត (Neonatal Mortality Rate) ត្រូវបានកាត់បន្ថយពី៣៧ ក្នុងមួយពាន់កំណើតរស់នៅឆ្នាំ២០០០ ដល់២៨នៅឆ្នាំ២០០៥ មកនៅ២៧នៅឆ្នាំ២០១០ និងចុះដល់១៨ក្នុងមួយពាន់កំណើតរស់នៅឆ្នាំ២០១៤។




៣.អត្រាមរណភាពកុមារអាយុក្រោមមួយឆ្នាំ (Infant Mortality Rate)ត្រូវបានកាត់បន្ថយពី ៩៥ក្នុងមួយពាន់កំណើតរស់នៅឆ្នាំ២០០០ ដល់៦៥នៅឆ្នាំ២០០៥ មកនៅ៤៥នៅឆ្នាំ២០១០ និងថយចុះដល់២៨ក្នុងមួយពាន់កំណើតរស់នៅឆ្នាំ២០១៤។




៤.អត្រាមរណភាពកុមារអាយុក្រោមប្រាំឆ្នាំ(Under-five Mortality Rate) បានថយចុះពី១២៤ ក្នុងមួយពាន់កំណើតរស់ ដល់៨៣នៅឆ្នាំ២០០៥ មកនៅ៥៤នៅ ឆ្នាំ២០១០និងបន្តថយចុះដល់៣៥ក្នុងមួយពាន់កំណើតរស់នៅឆ្នាំ២០១៤។




៥.អត្រានៃការមានកូនសរុបក្នុងស្ត្រីម្នាក់(Total Fertility Rate)បានថយចុះពី៤.0នៅឆ្នាំ២០០០មកនៅ៣.៤នៅឆ្នាំ២០០៥ បន្តថយចុះមកនៅ៣.0នៅឆ្នាំ២០១០ និងបានចុះមកនៅត្រឹម២.៧នៅឆ្នាំ២០១៤។




៦.អត្រានៃការសម្រាលកូនដោយបុគ្គលិកដែលបាន បណ្តុះបណ្តាល (Delivery by skilled birth attendant) មានការកើនឡើងពី៣២%នៅឆ្នាំ២០០០ ដល់៤៤% នៅឆ្នាំ២០០៥ ដល់៧១%នៅឆ្នាំ២០១០ និងបន្តកើនឡើងដល់៨៩%នៅឆ្នាំ២០១៤។




៧.អត្រានៃការសម្រាលកូននៅមូលដ្ឋានសុខាភិបាល (Delivery at health facility) មានការកើនឡើង ពី ១០%នៅឆ្នាំ២០០០ ដល់២២%នៅឆ្នាំ២០០៥ ដល់ ៥៤%នៅឆ្នាំ២០១០ និងកើនដល់៨៣%នៅឆ្នាំ ២០១៤។




៨.អត្រានៃស្ត្រីដែលទទួលបានការពិនិត្យផ្ទៃពោះយ៉ាងតិចមួយដង(ANC1) បានកើនពី៣៨% នៅឆ្នាំ២០០០ ដល់៦៩%នៅឆ្នាំ២០០៥ ដល់៨៩% នៅឆ្នាំ២០១០ និងបន្តកើនដល់៩៥%នៅឆ្នាំ២០១៤។ ស្ត្រីដែលទទួលបានការពិនិត្យផ្ទៃពោះចំនួនបួនដង (ANC4) បានកើនពី ៩%នៅឆ្នាំ២០០០ ដល់២៧% នៅឆ្នាំ២០០៥ កើនដល់៥៩%នៅឆ្នាំ២០១០ និងបន្ត កើនដល់៧៥%នៅឆ្នាំ២០១៤។




៩.អត្រានៃការប្រើមធ្យោបាយពន្យារកំណើតទំនើប (Modern Contraceptive Prevalence Rate) បានកើនពី១៩%នៅឆ្នាំ២០០០ ដល់២៧%នៅឆ្នាំ២០០៥ ដល់៣៥%នៅឆ្នាំ២០១០ និងកើនដល់៣៩%នៅឆ្នាំ ២០១៤។




១០.ការមិនទទួលបានសេវាពន្យារកំណើតតាមតម្រូវការ (Unmet need for family planning) បានកាត់បន្ថយពី៣៣%នៅឆ្នាំ២០០០ មក២៥%នៅឆ្នាំ២០០៥ មក ១៧%នៅឆ្នាំ២០១០ និង១៣%នៅឆ្នាំ២០១៤។

